# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខៈ ០០៣/០៨ របក.កកចនយ**

# របាយការណ៍

## ស្តីពី

## សកម្មភាពការងារប្រចាំ ២០០៧

## របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## និងទិសដៅសម្រាប់អនុវត្តបន្ត

នៅក្នុងឆ្នាំ ២០០៧ នេះ ចាប់ពីខែមករា ដល់ ខែធ្នូ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រង គម្រោងជាអង្គភាពប្រត្តិបត្តិបានដំណើរការងាររបស់ខ្លួនស្របតាមបេសកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយ សម្រេចបាននូវលទ្ធផលចាក់ស្តែងដូចខាងក្រោមៈ

**១.ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

- ធ្វើដីការអមរបាយការណ៍ស្តីពីការទស្សនាតុលាការខេត្តកណ្តាល កាលពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៦
- ទទួលរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ សម្រាប់ឆ្នាំ ២០០៦ ពីក្រសួងស្ថាប័នពាក់ព័ន្ធ
- ទទួលកម្រងសាលក្រមតុលាការកំពូល បញ្ជូនទៅបោះពុម្ពនៅអគ្គនាយកដ្ឋានរាជកិច្ច
- ទំនាក់ទំនង រៀបចំលិខិតអញ្ជើញ និងត្រៀមប្រជុំក្រុមប្រតិបត្តិគម្រោង PEG/A2J នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៧

- ទទួល និងរៀបចំលិខិតគាំទ្រសំណើរបស់វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចិម សុំពន្យាអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំលិខិតអញ្ជើញចូលរួមពិភាក្សា ស្តីពីការរៀបចំប្រព័ន្ធទិន្នន័យលើកកំពស់ការយល់ដឹងសិទ្ធិមូលដ្ឋាននៅ កំរិតសហគមន៍ នៅថ្ងៃព្រហស្បតិ៍ ទី២២ ខែមីនា ឆ្នាំ២០០៧ និងរៀបចំឯកសារពាក់ព័ន្ធ
- រៀបចំលិខិតអញ្ជើញចូលរួមប្រជុំ Sub-Group TWG និងរៀបចំឯកសារពាក់ព័ន្ធផ្សេងៗ
- រៀបចំលិខិតអញ្ជើញចូលរួមប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅថ្ងៃអង្គារ ទី២៤ ខែមេសា ឆ្នាំ២០០៧
- ផ្ញើលិខិតទៅលោក Wolfgang Meyer អ្នកតំណាងអង្គការ Konrad-adenauer Stiftung ស្តីពីសៀវភៅ ក្បួនសម្រាប់បង្កើតច្បាប់ (Handbook for Law Making) នៅថ្ងៃទី ១១ ខែមេសា ឆ្នាំ២០០៧
- ផ្ញើលិខិតទៅឯកឧត្តម ប៉ែន ដារេត ស្តីពីគម្រោង ដើម្បីសុំជំនួយពីអាល្លឺម៉ង់ នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០៧
- ធ្វើដីការអមទៅក្រសួង ស្ថាប័នពាក់ព័ន្ធ បញ្ជូនរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ឆ្នាំ២០០៦ តារាងស្តីពីស្ថានភាពនៃការនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រងលច្បាប់ និងតុលាការប្រចាំឆ្នាំ ២០០៦ និងបញ្ជីគម្រោងសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការជាសង្ខេប ដើម្បីទុកជាមូលដ្ឋានសម្រាប់ការប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧
- ធ្វើលិខិតស្នើសុំត្រៀបរបាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្តីពីតុលាការពាណិជ្ជកម្មសម្រាប់ការប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (ជូនចំពោះឯកឧត្តម ម៉ៅ ថូរ៉ា អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម)
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំពិនិត្យ ពិភាក្សាលើសេចក្តីព្រាងស្តងដា សម្រាប់តុលាការគំរូ នៅថ្ងៃព្រហស្បតិ៍ ទី១៧ ខែឧសភា ឆ្នាំ២០០៧
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៧
- លិខិតស្នើសុំរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាត់តាំងមន្ត្រីបច្ចេកទេសមួយរូប ដើម្បីចូលរួមជាសមាជិកក្រុមការងារបច្ចេកទេសក្នុងគម្រោងពង្រឹកបន្ថែមតុលាការគំរូនៅកម្ពុជា
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ក.ក.ច.ន.យ) នៅថ្ងៃពុធទី០៦ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង៩ៈ០០ ព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី

- លិខិតស្នើសុំជួយពិនិត្យកែសម្រួលសេចក្តីព្រាងរបាយការណ៍ ស្តីពីកិច្ចប្រជុំរបស់អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧
- ផ្ញើដីការអមសេចក្តីថតចម្លងរបាយការណ៍ស្តីពីកិច្ចប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧ និងអញ្ជើញប្រជុំក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧
- ផ្ញើលិខិតស្នើអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការនៅ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង ១៤ៈ៣០ នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្ញើលិខិតស្នើសុំចាត់តាំងអ្នកតំណាងដើម្បីចូលរួមជាសមាជិក នៃក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូ
- ផ្ញើសៀវភៅរបាយការណ៍នៃការសិក្សាស្រាវជ្រាវស្តីពី "ជំនួយផ្នែកច្បាប់នៅកម្ពុជា ៖ ការអនុវត្តការយល់ឃើញ និងតម្រូវការ" ជូនអ្នកពាក់ព័ន្ធ
- ផ្ញើសៀវភៅរបាយការណ៍ជំនួយផ្នែកច្បាប់នៅកម្ពុជា ៖ ការអនុវត្ត ការយល់ឃើញ និងតម្រូវការជូនអ្នកពាក់ព័ន្ធ
- ផ្ញើលិខិតស្នើសុំផ្លាស់ប្តូរកំរិត និងតម្លើងកំរិតប្រាក់មុខងារដល់មន្ត្រីនៃអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ផ្ញើរបាយការណ៍ស្តីពីសមិទ្ធិផលសំខាន់ៗនៃវិស័យកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (២០០៣-២០០៨) និងទិសដៅអនុវត្តបន្ត ជូនអ្នកពាក់ព័ន្ធ
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧ វេលាម៉ោង ១៥ៈ00 រសៀល
- ផ្ញើលិខិតសុំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ឆមាស ទី១ ឆ្នាំ២០០៧ ទៅក្រសួងពាក់ព័ន្ធ រួមមាន ៖ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- ផ្ញើលិខិតអញ្ជើញចូលរួមក្នុងបទបង្ហាញតាមរយៈវិដេអូឆ្លងឆ្លើយ (Video Conference)ស្តីពីទស្សនាទាននៃតុលាការគំរូ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧ នៅធនាគារពិភពលោក
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃពុធ ទី០៨ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ៩.០០ ព្រឹក

- ផ្ញើដីកាអមសេចក្តីថតចម្លងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្តីពីលទ្ធផលសំខាន់ៗនៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ឆ្នាំ២០០៦ កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧
- ផ្ញើលិខិតទៅអភិបាលខេត្តពោធិ៍សាត់ ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៧ះ៣០ នាទីព្រឹក
- ផ្ញើលិខិតទៅអភិបាលខេត្តកំពង់ចាម ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៧.៣០ នាទីព្រឹក
- ផ្ញើលិខិតទៅអភិបាលខេត្តមណ្ឌលគីរី ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ៧.៣០ នាទីព្រឹក
- ផ្ញើបញ្ជីឈ្មោះមន្ត្រីរាជការនៃអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសសម្រាប់ឆ្នាំ ២០០៧ ទៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានរៀបចំសេចក្តីសម្រេចស្តីពីសមាសភាពក្រុមការងារបច្ចេកទេសតុលាការគំរូ
- លិខិតស្នើកែខ្លឹមសារចំណុច ៥.១ នៃសារាចរស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ
- ផ្ញើដីកាអមរបាយការណ៍កិច្ចប្រជុំស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករ និងតាមដានរួម លេខ ០២២ /០៧ របក.អសអ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៧ និង លេខ ០២៣/០៧ របក.អសអ កាលពីថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៧
- ផ្ញើលិខិតឯកភាពចំពោះការស្នើឱ្យមន្ត្រីជំនាញបីរូបរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិ ការកិច្ច មកធ្វើការស្រាវជ្រាវលើផ្នែកពាក់ព័ន្ធនឹងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ
- ផ្ញើលិខិតស្នើទៅតាមក្រសួងនានា ដើម្បីជួយបំពេញបញ្ជីរាយឈ្មោះច្បាប់ (Law Catalogue) និងព័ត៌មានទាក់ទងនឹងអង្គភាពនីតិកម្មរបស់ក្រសួង
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំអនុក្រុមទី ១ ការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និង តុលាការ នៅថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៨.០០ ព្រឹក
- ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការរៀបចំ និងអនុវត្តគម្រោងតុលាការគំរូនៅកម្ពុជា នៅ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៨.៣០ នាទីព្រឹក

- ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការរៀបចំ និងការអនុវត្តគម្រោងតុលាការគំរូនៅកម្ពុជា នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៧
- ផ្ញើតារាងភាពជឿនលឿននៃការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ ឆមាសទី១ ឆ្នាំ២០០៧ ក្នុងក្របខ័ណ្ឌ GAP II ទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។
- ផ្ញើលិខិតស្នើទៅក្រសួងពាក់ព័ន្ធ សុំចាត់តាំងតំណាង ១ រូប ជាសមាជិកក្រុមការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១៤.៣០នាទី
- ផ្ញើលិខិតអញ្ជើញចូលរួមពិភាក្សាលក្ខណៈវិនិច្ឆ័យ និងស្តង់ដាតុលាការគំរូ ពីថ្ងៃទី ០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅសាលប្រជុំអង្គភាពគ្រប់គ្រងគម្រោង
- ផ្ញើលិខិតស្នើសុំផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍វាយតម្លៃហិរញ្ញប្បទានសម្រាប់ប្រទេសកម្ពុជា (Cambodia Country Assistance Evaluation)របស់ក្រុមវាយតម្លៃឯករាជ្យ (Independent Evaluation Group, IEG) នៃធនាគារពិភពលោក
- ផ្ញើលិខិតស្នើសុំចាត់តាំងអ្នកតំណាង ១ រូប ជាសមាជិកក្រុមការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា (Access to Justice) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០០៧ វេលាម៉ោង ៨.៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំអនុក្រុមទី ១ ការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និង តុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៧ វេលាម៉ោង ៩.០០ ព្រឹក នៅសាលប្រជុំអង្គភាពគ្រប់គ្រងគម្រោង
- ផ្ញើដីកាជូនអមជូនក្រសួង ស្ថាប័នពាក់ព័ន្ធ នូវសេចក្តីបន្ថែមទៅលើឯកសារគម្រោង ឧបត្ថម្ភដោយទីភ្នាក់ងារអេស្បាញ ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ និងរបាយការណ៍ពិនិត្យសារឡើងវិញប្រចាំឆ្នាំសម្រាប់កិច្ចប្រជុំ នៅថ្ងៃសុក្រ ទី៧ ខែធ្នូ ឆ្នាំ២០០៧។

## ខ. ការងារកំណែទម្រង់

*+ ការងារពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយ*

រៀបចំរបាយការណ៍ប្រចាំឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- បញ្ចប់របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ និងធ្វើការចែកជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធ

  រៀបចំរបាយការណ៍នៃភាពជឿនលឿន ឆមាសទី II សម្រាប់ GAP II
- ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង ដើម្បីពង្រឹងការអនុវត្តការងារឆ្នាំថ្មី
- ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង ដែលជាអ្នកសម្របសម្រួលក្នុង Sub-Group នីមួយៗជាមួយនឹងថ្នាក់ដឹកនាំ PMU និងទីប្រឹក្សាមកពី AusAid ដើម្បីស្វែងយល់អំពីរូបមន្ត ដើម្បីធ្វើឱ្យមុខងារសម្របសម្រួលមានប្រសិទ្ធិភាពខ្ពស់
- ប្រជុំអនុក្រុមការងារផ្សេងៗ ដើម្បីធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ រៀបចំក្រង Project Profile
- ប្រជុំពិនិត្យចុងក្រោយនូវ Project Profile និងពិភាក្សាអំពីដំណើរការនៃក្រុមការងារ Sub-Group TWG
- ប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧ ដើម្បីពិនិត្យលទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់ការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ និងទិសដៅសម្រាប់ការអនុវត្តជាបន្ត
- រៀបចំប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧
- ប្រជុំអង្គភាពគ្រប់គ្រងគម្រោង ពិភាក្សាលើការរៀបចំ Website របស់អង្គភាព នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧
- ប្រជុំពង្រឹងសមត្ថភាពមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៅថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៧
- ប្រជុំអង្គភាពគ្រប់គ្រងគម្រោងអំពីយុទ្ធសាស្ត្រក្នុងការទំនាក់ទំនង (Communication Strategy) នៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៧
- ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង រៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងកម្មវិធីការងារ និងរៀបចំការប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ TWG/Model Court
- ប្រជុំកែសម្រួលនីតិវិធីនៃការតាក់តែងច្បាប់ ជាមួយក្រុមការងារទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំតារាងអនុវត្តការងារកំណែទម្រង់ច្បាប់ និងតុលាការ សម្រាប់ឆ្នាំ២០០៧-២០០៨
- កែសម្រួលសេចក្តីព្រាងតារាងស្តីពីស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ
- រៀបចំព្រាងរបាយការណ៍ស្តីពីការអនុវត្តសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ឆមាសទី ២ ឆ្នាំ២០០៧
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តពោធិ៍សាត់ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៧

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តកំពង់ចាម នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៧
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តមណ្ឌលគីរី នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧។

*+ កិច្ចប្រជុំទាក់ទងទៅនឹងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា*

- ប្រជុំជាមួយតំណាង UNDP រៀបចំបែងចែកថវិការចំណាយសម្រាប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា ឆ្នាំ២០០៧ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៧
- ប្រជុំក្រុមប្រតិបត្តិគម្រោង (PEG/A2J) ពិនិត្យអនុម័តគម្រោងថវិកាចំណាយឆ្នាំ ២០០៦ សម្រាប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា (A2J)
- ប្រជុំ PEG/A2J ដើម្បីអនុម័តរបាយការណ៍ ២០០៦ និងអនុម័តផែនការការងារ និងថវិកាប្រចាំឆ្នាំ ២០០៧
- ប្រជុំជាមួយនឹងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ត្រៀមរៀបចំសិក្ខាសាលាស្តីពីការបង្កើតប្រព័ន្ធទិន្នន័យ អំពីកម្មវិធីលើកកំពស់ការយល់ដឹងសិទ្ធិមនុស្សនៅមូលដ្ឋាន
- ប្រជុំពិគ្រោះយោបល់ជាមួយអង្គការ ក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ស្តីពីការរៀបចំប្រព័ន្ធទិន្នន័យលើកកំពស់ការយល់ដឹងសិទ្ធិមូលដ្ឋាន
  នៅកំរិតសហគមន៍ដោយមានការសហការជាមួយនឹងកម្មវិធីអភិវឌ្ឍន៍អង្គការ សហប្រជាជាតិ (UNDP)នៅថ្ងៃព្រហស្បតិ៍ ទី២២ ខែមីនា ឆ្នាំ២០០៧
- ជួយពិភាក្សាជាមួយអ្នកតំណាងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដោះស្រាយបញ្ហាពាក់ព័ន្ធដល់ការរៀបចំប្រព័ន្ធទិន្នន័យគម្រោងលេខ ១.១.១ (សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា) នៅថ្ងៃ ទី១១ ខែមេសា ឆ្នាំ២០០៧
- ជួបប្រជុំនៅ UNDP ស្តីពីចំនុចសំខាន់ៗនៃប្រព័ន្ធទិន្នន័យកម្មវិធីការលើកកំពស់ការយល់ដឹងសិទ្ធិមនុស្សនៅមូលដ្ឋាន
- ចូលរួមប្រជុំជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ជ្រើសរើសអ្នកជំនាញរៀបចំប្រព័ន្ធទិន្នន័យស្តីពីការបណ្តុះបណ្តាលសិទ្ធិមនុស្ស (Human Rights Training)
- ជួបពិភាក្សាជាមួយក្រុមការងាររៀបចំ Database នៅកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)
- ចូលរួមពិភាក្សាជាមួយអ្នកតំណាង UNHCHR លើការបន្តនិរន្តរភាពគម្រោងលើកកំពស់សិទ្ធិមនុស្សនៅមូលដ្ឋាន

- ជួបពិភាក្សាជាមួយក្រុមហ៊ុនរៀបចំ Database ស្តីពីការបណ្តុះបណ្តាលសិទ្ធិមនុស្ស (Human Right Training)
- ចូលរួមសម្ពោធមណ្ឌលសេវាកម្មយុត្តិធម៌ នៅស្រុកទឹកផុស និងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- ទទួលជួបក្រុមការងារ UNDP វាយការណ៍ពីលទ្ធផលនៃការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌ (Access to Justice) នៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៧។

*+ កិច្ចប្រជុំរបស់ក្រុមបច្ចេកទេសចម្រុះ*

- ចូលរួមប្រជុំ GDCC នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)
- ប្រជុំក្រុមការងារបច្ចេកទេសចម្រុះ (technical Working Group) នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០០៧
- រៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៧
- ប្រជុំអនុក្រុម (Sub-Group)
- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ២០:៣០ នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី
- កិច្ចប្រជុំអនុក្រុមទី ១ ការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ៨០:០០ ព្រឹក
- ប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទី ២ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧
- ប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១៤០:៣០នាទី
- ប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះទី ៤។

*+ CCJAP (តុលាការគំរូ )*

- ប្រជុំអង្គភាពគ្រប់គ្រងគម្រោង ពិនិត្យ កែសម្រួលស្តង់ដារតុលាការគំរូ (Standard Model Court) នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៧
- រៀបចំប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងស្តង់ដា (Standard)សម្រាប់តុលាការគំរូ នៅថ្ងៃព្រហស្បតិ៍ ទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧
- ចូលរួមប្រជុំពិនិត្យគម្រោង CCJAP III នៅក្រុងព្រះសីហនុ នៅថ្ងៃទី២៥-២៦-២៧ ខែមេសា ឆ្នាំ២០០៧
- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧ វេលាម៉ោង ១៥.០០ រសៀល

- រៀបចំប្រជុំការងារបច្ចេកទេសតុលាការគំរូ បទបង្ហាញតាមរយៈវីដេអូឆ្លងឆ្លើយ (Video Conference) ស្តីពីទស្សនាទាននៃតុលាការគំរូ ជាមួយ DIHR ពីដាណឺម៉ាក នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ នៅធនាគារពិភពលោក (World Bank)
- រៀបចំកិច្ចប្រជុំស្តីពីការរៀបចំ និងអនុវត្តគម្រោងតុលាការគំរូនៅកម្ពុជា នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៧ នៅអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កិច្ចប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ រៀបចំស្តង់ដាលក្ខណៈវិនិច្ឆ័យ នៅថ្ងៃទី ០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅសាលប្រជុំអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ទទួលជួបពិភាក្សាជាមួយក្រុមការងារវាយតម្លៃការអនុវត្តគម្រោង CCJAP III នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧

*+ កិច្ចប្រតិបត្តិការទាក់ទងនឹងជំនួយផ្នែកច្បាប់*

- ជួបពិនិត្យរបាយការណ៍បញ្ចប់ស្តីពីការស្ទង់មតិអំពីជំនួយផ្នែកច្បាប់ ជាភាសាអង់គ្លេស
- ជួបពិភាក្សាជាមួយគណៈមេធាវីកម្ពុជា លើរបាយការណ៍នៃការស្ទង់មតិ អំពីជំនួយផ្នែកច្បាប់នៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៧
- បញ្ចប់ការកែលំអរបាយការណ៍លើការស្ទង់មតិជំនួយផ្នែកច្បាប់ (ជាភាសាខ្មែរ)

*+ ការងាររៀបចំប្រព័ន្ធសូចនាករ*

- រៀបចំប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៧
- ប្រជុំផ្ទៃក្នុងពិនិត្យ រៀបចំសូចនាករតាមដានរួម ប្រចាំឆ្នាំ ២០០៧ នៅថ្ងៃទី ២ ខែឧសភា ឆ្នាំ ២០០៧
- ប្រជុំអង្គភាពគ្រប់គ្រងគម្រោងជាមួយអ្នកផ្តល់ជំនួយសំខាន់ៗ ពីរឿងរៀបចំប្រព័ន្ធសូចនាករកំណែទម្រង់ នៅ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០០៧
- រៀបចំកិច្ចប្រជុំស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃពុធ ទី០៨ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ៩ៈ00 ព្រឹក
- រៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារជាន់ខ្ពស់ប្រព័ន្ធសូចនាករ និងតាមដានកំណែទម្រង់ច្បាប់ និងតុលាការ
- ជួបពិភាក្សាជាមួយក្រុមការងាររៀបចំ ស្តីពីការរៀបចំប្រព័ន្ធសូចនាករកំណែទម្រង់ច្បាប់ និងតុលាការ
- ទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

***+ ការងារទំនាក់ទំនង និងការផ្សព្វផ្សាយ***

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅតាមខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង
- ទទួលជួបក្រុមការងារវាយតម្លៃគម្រោង CCJAP III/AusAid ដើម្បីការងារពង្រឹងសហប្រតិបត្តិការទៅថ្ងៃមុខ
- ទទួលជួបជាមួយតំណាងអង្គការ DANIDA នៅកម្ពុជាដើម្បីពង្រឹងការងារទំនាក់ទំនង
- ធ្វើការពិភាក្សាជាមួយតំណាង DIHR លោក Anders Buhelt និង Bent Vase ដើម្បីតាក់តែង Project Document និង Cooperation Agreement រវាង PCB/PMU DIHR សម្រាប់ឆ្នាំ២០០៧។
- ជួបជាមួយតំណាង DIHR ពិភាក្សាលើការងារកិច្ចសហប្រតិបត្តិការឆ្នាំថ្មី នៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៧
- ទទួលជួបក្រុមការងារ IFC ស្វែងយល់ពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងវិស័យពាណិជ្ជកម្ម
- ទទួលជួបក្រុមការងារ GTZ ដឹកនាំដោយលោក Luc de Meester ស្វែងយល់ពីគម្រោងអាទិភាពនៃកំណែទម្រង់ច្បាប់ និងតុលាការ
- ទទួលជួបគណៈប្រតិភូ DIHR ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងDIHR។

***+ ការពិនិត្យនីតិវិធីនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត***

***-ចូលរួមពិនិត្យកែលំអរសៀវភៅស្តីពីវិធាន*** និងនីតិវិធីនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានជាមួយអគ្គលេខាធិការាជរដ្ឋាភិបាល

**គ. ផ្សេងៗ**

- ចូលរួមរៀបចំវេទិកាសម្រាប់ព្រឹទ្ធសភា និងរដ្ឋសភា ស្តីពីកំណែទម្រង់រដ្ឋរបស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៧។
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយឯកសារស្រាវជ្រាវរបស់វិទ្យាស្ថានអភិវឌ្ឍន៍សង្គម នៅសណ្ឋាគារ HIMA WARI
- ចូលរួមរៀបចំសន្និសីទស្តីពីអភិបាលកិច្ចលើកទី ២ ក្រោមអធិបតីភាពសម្តេចនាយករដ្ឋមន្ត្រី នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៧ នៅសាលចតុមុខ ។

- ចូលរួមវគ្គបណ្តុះបណ្តាលច្បាប់ពាណិជ្ជកម្មអន្តរជាតិ (International Trade Law) រយៈពេល ៤ ថ្ងៃ ពីថ្ងៃទី ២៦ ដល់ ២៩ ខែមីនា ឆ្នាំ២០០៧ ដោយមានការឧបត្ថម្ភពីក្រសួងការបរទេស និងសហប្រតិបត្តិការសឹង្ហបូរី
- ទទួលជួបក្រុមការងារនៃធនាគារពិភពលោក (World Bank) ស្វែងយល់ពីបរិយាកាសនៃការកែទម្រង់ច្បាប់ និងតុលាការ
- ទទួលជួបអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ របស់អង្គការពាណិជ្ជកម្មពិភពលោក(ILO)បង្ហាញពីគម្រោងបណ្តុះបណ្តាលជនជាតិភាគតិចនៅរតនគីរី
- ចូលរួមពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងកម្មវិធី AusAid នៅក្រសួងមហាផ្ទៃ
- ទទួលជួបក្រុមការងាររបស់ CSD (Centre Social Development) សុំមតិយោបល់លើរបាយការណ៍ផ្សេងៗ ដែលអង្គការបានផ្សព្វផ្សាយ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧
- ទទួលប្រជុំពិនិត្យរបាយការណ៍វាយតំលៃលើកម្មវិធី CCJAP II នៅក្រសួងយុត្តិធម៌ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧
- ចូលរួមប្រជុំពិនិត្យរបាយការណ៍ស្តីពីភាពជឿនលឿនក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ នៅក្រសួងផែនការ
- ចូលរួមប្រជុំនៅសាលាភូមិន្ទរដ្ឋបាល (L'Ecole Royale d'Administration) ពិនិត្យកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងសាលាភូមិន្ទរដ្ឋបាល និងសាកលវិទ្យាល័យស៊ីដនី
- ចូលរួមការប្រជុំគណៈកម្មការ GDCC សម្រាប់រៀបចំ CDCF លើកទី ១ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០៧
- ចូលរួមពិធីចុះហត្ថលេខាកិច្ចសហប្រតិបត្តិការបារាំង សាលាចៅក្រមលើការងារបណ្តុះបណ្តាល នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៧
- ចូលរួមសន្និសីទខួបទី ៥០ ឆ្នាំរបស់សហភាពអឺរ៉ុប និងខួបលើកទី ៤០ ឆ្នាំរបស់អាស៊ាន និងខួប ១ ឆ្នាំរបស់ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់
- ចូលរួមប្រជុំពិនិត្យរបាយការណ៍ស្តីពីភាពជឿនលឿនអភិបាលកិច្ច II ឆមាសទី II ២០០៦
- ចូលរួមប្រជុំពិនិត្យតម្លើងកាំបៀវត្សជូនមន្ត្រីរាជការ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមសិក្ខាសាលានៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការធ្វើអង្កេតលើសំណើសុំហិរញ្ញប្បទាន សហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុនសម្រាប់ឆ្នាំ ២០០៨
- ចូលរួមប្រជុំ CCJAP III នៅក្រសួងមហាផ្ទៃ នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៧

- ចូលរួមប្រជុំតុមូល ពិភាក្សាលើសេចក្ដីព្រាងច្បាប់តុលាការពាណិជ្ជកម្ម នៅកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ( UNDP) នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៧
- ចូលរួមសិក្ខាសាលាស្ដីពីសេចក្ដីព្រាងអនុក្រឹត្យបង្កើតមជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្ម នៅសណ្ឋាគារ HIMA WARI រៀបចំដោយក្រសួងពាណិជ្ជកម្ម ។
- បញ្ជូនសំណើសុំជំនួយឧបត្ថម្ភពីជប៉ុន នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)
- ចូលរួមសិក្ខាសាលាសិទ្ធិទទួលបានព័ត៌មាន នៅសណ្ឋាគារភ្នំពេញ រៀបចំដោយក្រសួងទំនាក់ទំនងសភា
- ទទួលជួបក្រុម Transparency International ធ្វើបទឧទ្ទេសនាមបង្ហាញពីអំពើពុករលួយក្នុងប្រព័ន្ធតុលាការកម្ពុជា
- ចូលរួមពិធីប្រគល់វិញ្ញាបនប័ត្រមេធាវី នៅសាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន**
- ពិនិត្យកែសម្រួលសេចក្ដីព្រាងសារាចរស្ដីពីនីតិវិធី និងវិធាននៃការតាក់តែងលិខិតបទដ្ឋាន
- ចូលរួមប្រជុំរៀបចំគោលការណ៍ភាពជាដៃគូជាមួយប្រទេសអង់គ្លេស នៅក្រុមប្រឹក្សាអភិវឌ្ឍន៍ ម្ពុជា (CDC) នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧
- ចូលរួមប្រជុំក្រុមការងារពង្រឹងសាលាភូមិន្ទរដ្ឋបាល នៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០០៧
- ពិនិត្យកែលំអសេចក្ដីព្រាងនីតិវិធីតាក់តែងច្បាប់ និងចូលរួមប្រជុំក្រុមការងារនីតិវិធីតាក់តែងច្បាប់នៅ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយការប្រើប្រាស់អក្សរក្រមខ្មែរក្នុងប្រព័ន្ធកំព្យូទ័រ (Unicode) នៅ ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០០៧ នៅសណ្ឋាគារ SUNWAY
- ចូលរួមសិក្ខាសាលាស្ដីពីការវាយតម្លៃលើការអនុវត្តគម្រោង PMG ក្រោមអធិបតីភាពរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ នៅ សណ្ឋាគារ Inter-Continental
- ចូលរួមអន្តរក្រសួងពិភាក្សាសេចក្ដីព្រាងច្បាប់ស្ដីពីទូរគមនាគមន៍
- ចូលរួមកែលំអសេចក្ដីព្រាងនីតិវិធីនៃការតាក់តែងច្បាប់ជាមួយក្រុមការងារទីស្ដីការគណៈរដ្ឋមន្ត្រី
- ចូលរួមស្ដាប់សវនាការលើកទី១ អង្គជំនុំជំរះវិសាមញ្ញខ្មែរក្រហម នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០៧
- ធ្វើរបាយការណ៍ស្ដីពីការពង្រឹងនីតិរដ្ឋ (២០០៣-២០០៨) និងទិសដៅអនុវត្តជាបន្តជូនទីស្ដីការ គណៈរដ្ឋមន្ត្រី។

## ២. សន្និដ្ឋាន

ក្នុងឆ្នាំ ២០០៧ នេះ អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានបំពេញការងារយ៉ាងសកម្ម ជាពិសេសលើការងាររៀបចំបញ្ជីគម្រោងសម្រាប់ចែកជូនអង្គការ ក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យ

ធ្វើសមទិន និងការជម្រុញការអនុវត្តកម្មវិធីសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា (A2J) ដោយកិច្ចសហការពីអង្គការ UNDP។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌ បានបញ្ចប់នូវទិសដៅចំបងរបស់ខ្លួនដោយជោគជ័យ ពោលគឺបានធ្វើការប្រជុំអនុក្រុមការងារបច្ចេកទេស ឈានទៅរៀប ចំសេចក្តីព្រាងតារាង ស្តីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ផ្ញើជូនក្រសួង ស្ថាប័ន ដើម្បីស្នង់មតិយោបល់កែលំអរ និងបានជំរុញការអនុវត្តគម្រោងផ្សេងៗក្រោមការ ទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឱ្យទទួលបានលទ្ធផលទៅតាមការគ្រោងទុក។

**៣. ទិសដៅអនុវត្តបន្ត**

***+ បន្តជំរុញការអនុវត្តគម្រោង:***

- តុលាការគំរូ

-ប្រព័ន្ធសូចនាករ និងការតាមដាន

- ប្រព័ន្ធទិន្នន័យស្តីពីការលើកកម្ពស់សិទ្ធិមនុស្ស ដោយពិភាក្សាជា UNDP ដើម្បីឱ្យបន្តជំនួយឧបត្ថមលើគម្រោងនេះ

+ ពិភាក្សាការបន្តសហប្រតិបត្តិការជាមួយ DIHR ក្នុងការជួយឧបត្ថមការងាររបស់ PCB និង PMU ។

+ ពិភាក្សាការបន្តសហប្រតិបត្តិការជាមួយ DANIDA និង CCJAP III ក្នុងការឧបត្ថមកំណែ ទម្រង់ច្បាប់ និងតុលាការសម្រាប់ពីរឆ្នាំទៅមុខទៀត។

+ បន្តការពិភាក្សាជាមួយ EU ក្នុងការឧបត្ថមដល់ការអនុវត្តគម្រោងខ្លះ

+ ពិភាក្សាជាមួយក្រុមការងារ USAID ដើម្បីផ្តល់មតិដល់ការរៀបចំកម្មវិធីជំនួយឧបត្ថមសម្រាប់ រយៈពេល៥ឆ្នាំទៅមុខ

+ បន្តធ្វើទំនាក់ទំនង ផ្សព្វផ្សាយ ស្វែងរកដៃគូអភិវឌ្ឍន៍លើគម្រោងថ្មីៗថែមទៀត។

*រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**ហ៊្សឹង សុគុល**

ស៊ុយ ម៉ុងលាង